# ញ

ញ ព្យញ្ជនៈទី៩ ក្នុងវគ្គទី២ ជាសកវគ្គនាសិកដ្ឋានជៈ មានសំឡេងកើតក្នុងឋាន ២ គឺ ពីតាលុនិងច្រមុះ ។ ញ នេះ ខ្មែរប្រើបានសំឡេង ២ គឺ ជាឃោសៈក៏បាន ជាអឃោសៈក៏បាន ដូចជា *ញក, ញាត់, ញៀត* ជាដើម ជាឃោសៈ; *ញ៉ម, ញ៉ាម, ញ៉ាំង, ញ៉េះ, ញ៉ោះ* ជាដើម ជាអឃោសៈ; *កញ្ញា, សញ្ញា* (—ក័ញ-ញ៉ា, ស័ញ-ញ៉ា) ជាដើម ជាអឃោសៈ ។ កាលបើមានអក្សរខ្លួនឯងនៅរៀងពីខាងដើម ត្រូវតែប្រែក្លាយឯងជា *ញ្ញ* ទាំងពុំបាន ដូចជា *កញ្ញា, សញ្ញា, បញ្ញា, វិញ្ញាណ* ។ល។

**ញ** ១ *ន.* ឈ្មោះឈើមានផ្លែប្រើជាថ្នាំឬជាអាហារ ស្លឹកក៏ប្រើជាអាហារបាន; ញមានពីរប្រភេទគឺ *ញស្រុក* មួយ, *ញព្រៃ* មួយ; ញព្រៃមិនប្រើផ្លែឬស្លឹកជាអាហារពុំបានទេ ។

**ញ** ២ *គុ.* ដែលមានសណ្ឋានដូចផ្លែ ញ : *ដោះញ, ស្ត្រីដោះញ* (ប្រើចំពោះតែដោះស្ត្រី) ។

**ញក** *ន.* ទីដែលលយចេញទៅខាងក្រៅ : *ញកភ្នំ, ញកផ្ទះ* ជាដើម ។

**ញក់** *ប.*– ពាក្យបរិករសម្រាប់និយាយផ្សំនឹងពាក្យញី : *ញក់ញី* ឬ *ញីញក់* គឺញីរឿយៗ, ញីហើយញីទៀត ។

**ញប់** *គិ.* ឬ *គិ. វិ.* ញាប, ទប់ : *ទៅកុំញប់* (ប្រើដោយស្រុក) ។

**ញញ័រ** *គុ.* ឬ *គិ. វិ.* ដែលញ័រទទ្រើកដោយរងា ឬដោយខ្លាច, ដោយរំភើប : *ញ័រញញ័រ; ញើញញ័រ*។ *ញញ័រញញាក់* ដែលញ័រញាក់ទទ្រាក់ទទ្រើក ។

**ញញាក់** *គុ.* ឬ *គិ. វិ.* ដែលញ័រកន្ត្រាក់រឿយៗ, ញាក់រឿយៗ ។ *ញញាក់ញញ័រ* ដែលញ័រញាក់ទទ្រាក់ទទ្រើក ។

**ញញឹម** ឬ **ញញឹម** *គិ.* សើចបិទមាត់មិនបញ្ចេញសំឡេង : *គាត់គ្រាន់តែញញឹម ៗ* ប្រើជា *គុ.* ក៏បាន : *មុខញញឹម, ស្រស់ញញឹម* ។

**ញញី** *ប.* ពាក្យបរិករសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ញ័រ : *ញញីញញ័រ* ញ័រទទីទទ័រ ។



**ញញួរ** *ន.* ឧបករណ៍ស្លាបស្លាគូបធ្វើដោយដែក ជាប្រដាប់សម្រាប់ដាំដង, ដាំដែក, ដាំឈើ ។

**ញញើត** *គិ.* ព្រាក, ស្ទាក់ស្ទើរ, ប្រែង : *ខ្ញុំមិនហ៊ានទៅទេ ដូចជាញញើតណាស់* ។

**ញញើម** *ប.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ញញើត : *ញញើតញញើម* គឺញញើតដោយច្រើន ចេះតែញញើតឡើង, សង្ខែងអាការៈញ៉េបៗ ។

**ញញែម** *ប.* ពាក្យបរិករសម្រាប់និយាយផ្សំនឹងពាក្យ ញញឹម : *ញញឹមញញែម* គឺញញឹមព្រាយៗច្រើនពេកប្រឡែងតាមអាយ ។

**ញញោប** *ប.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ញញាក់ : *ញញាក់ញញោប* គឺញាក់ៗញោបៗ ។

**ញត្តិ** (ញ័ត-តិ) *ន.* (បា.; សំ. *ជ្ញប្តិ*) វាចាដែលភិក្ខុរូបមួយស្មូត្រប្រកាសឲ្យជំនុំសង្ឃដឹង គឺសម្ដីដែលភិក្ខុស្មូត្រឆ្លៀងជំនុំសង្ឃ ក្នុងការធ្វើសង្ឃកម្មដែលមានចម្រាប់ថា ត្រូវឲ្យឆ្លៀងជំនុំសង្ឃដែលមកប្រជុំក្នុងទីនោះជាមុន ទើបធ្វើបាន, ដើម្បីឲ្យដឹងថា សង្ឃកម្មនោះ ត្រឹមត្រូវតាមវិន័យហើយ ឬមានខុសដោយហេតុណាមួយ (ពាក្យសម្រាប់ប្រើក្នុងវិន័យខាងព្រះពុទ្ធសាសនា) ។ *ញត្តិ*- សព្ទនេះមកពី *ញា* "ដឹង, យល់, ស្គាល់" ប៉ុន្តែ *តិ*-បច្ច័យជា *ញាតិ*, សម្រេចរូបមកទៀតជា *ញត្តិ* "សម្ដីប្រកាសឲ្យយល់ឲ្យដឹង" ។ ប្រើជាសាធារណៈក៏បាន, មានន័យថា *ញត្តិស្រប, ញត្តិផ្ទាស់* ឬហៅថា *ញត្តិយល់ស្រប, ញត្តិយល់ផ្ទាស់* ក៏បាន ។ ពាក្យទម្លាប់ពីបុរាណ តែងតែមានពាក្យ *ញត្តិ* នេះជា *ញាត់* ចំពោះសង្ឃកម្មខ្លះៗ មានពិធីបំបួសកុលបុត្រជាភិក្ខុនិងកឋិនជាដើម : *ស្មូត្រញត្តិនាគ* ឬ *ញត្តិនាគ* (ស្មូតញាត់នាក ឬញាត់នាក) ស្មូត្រញត្តិក្នុងពិធីបំបួសកុលបុត្រដែលសន្មតនាមជានាគឲ្យទៅជាភិក្ខុ; *ញត្តិកឋិន* (ញាត់កៈថិន) ស្មូត្រញត្តិក្នុងកិច្ចកឋិន ។ល។

**ញត្តិកម្ម** (ញ័ត-តិ-ក័ម) *ន.* (បា.) សង្ឃកម្មដែលមានតែញត្តិមិនបាច់មានអនុស្សាវនា (ម. ព. *សង្ឃកម្ម* និង *អនុស្សាវនា* ផង; ព. វិ. ពុ.) ។

**ញត្តិចតុត្ថកម្ម** (ញ័ត-តិ-ច: តុត-ថ: ក័ម) *ន.* (បា.) សង្ឃកម្មដែលមាន *កម្មវាចា* ៣ ដង ជាគម្រប់ ៤ ដងនឹង *ញត្តិ* គឺសង្ឃកម្មដែលភិក្ខុស្មូត្រញត្តិរួចហើយ មានស្មូត្រប្រកាសសេចក្ដីនោះ បញ្ជាក់ ៣ ដងថែមទៀតដដែលៗ សម្រេចជាការត្រឹមត្រូវពិតប្រាកដហើយ (ព. វិ. ពុ.) ។

**ញត្តិទុតិយកម្ម** (ញ័ត-តិ-ទុតិយ:ក័ម) *ន.* (បា.) សង្ឃកម្មដែលមាន *កម្មវាចា* ១ លើក ជាគម្រប់ ២ លើកនឹង *ញត្តិ* គឺសង្ឃកម្មដែលមាន *ញត្តិ* ១ លើក *កម្មវាចា* ១ លើក ។ ព. វិ. ពុ. ។ (ម. ព. *ញត្តិ* និង *អនុស្សាវនា*

និង សន្សំកម្ម ផង ) ។

ញួន កិ. រួត (ព. អ.) ។

ញុបៗ កិ. វិ. សម្លេង ព្រួចខ្លះដោយខ្លាច ដោយញាប់ញ័រ: ញ័រញុបៗ (ម. ព. ញើបៗ ផង) ។

ញ៉ុម កិ. (ស. ញ៉ុម; ស. យ៉ម "ព្រម, យល់ព្រម") ព្រមទទួលចាញ់, ចុះចាញ់, ជាក់ចិត្ត ជាលែងហ៊ានទៀត : មិនសុំញ៉ុម, ទទួលញ៉ុម ។

ញយ ន. ជា កិ. វិ. ញឹក : សុំញយ, ទៅញយៗ ។ ញយដង ច្រើនដង, ញឹកញយ ។

ញ៉ូរ កិ. កន្ត្រាក់ទាញ, កន្ត្រាក់ផ្ដាច់ ។

ញ៉ល់ កិ. រុញ, រុក, ទល់ចង្កេះ, ស្រហាវ ។

ញ៉ាក់ កិ. ទាញកន្ត្រាក់ចំហៀង: ញ៉ាក់ក (ម. ព. ក្រ៊ក) ។ ព. ប្រ. បំបែរឲ្យតាមតាម, គំរាមតាម: មនុស្សនុះល្ងង់ណាស់ តាមតែអ្នកណាញ៉ាក់ឲ្យទៅទីណាក៏ទៅតែបាន ។ កន្ត្រាក់ទាញ, ញ៉ាទាញ: សរសៃញ៉ាក់ ឬ ញ៉ាក់សរសៃ ។ ធ្វើឲ្យកន្ត្រាក់ឃើញ, ញោចឡើង: ញ៉ាក់ចិញ្ចើម, ញ៉ាក់មុខ ។

ញ៉ាក កិ. (ឃ.) ខ្លាច, ញញើត, ញ៉មចុះចាញ់: វាញ៉ាកគេហើយ មិនហ៊ានចូលមកទៀតទេ ។

ញ៉ាប់! ឧ. ញ៉ាប់; ពាក្យបន្ទីដោយភ្ញាក់ភ្ញាំងមាត់, ច្រឡូសមាត់ (ព. អ.) ។

ញាណ (ញាន) ន. (បា.; សំ. ជ្ញាន) សេចក្ដីដឹង, ប្រាជ្ញា ... : ទ្រង់ញាណ (ព្រះពុទ្ធ) ទ្រង់ជ្រាបច្បាស់នូវកិច្ចការអាថ៌កំបាំងជ្រាលជ្រៅផ្សេងៗ ដោយព្រះប្រាជ្ញា; គេតែងប្រើពាក្យ ទ្រង់ញាណនេះ ក្នុងការស្ដីបន្ទោសផ្ដាច់ថា: អ្នកនេះណាទ្រង់ញាណដូចព្រះទេ, បើនឹងមិនប្រាប់ធ្វើម្ដេចឲ្យគេដឹងដូចបាន? បើប្រើរៀងក្រោយពីខាងដើមសព្ទដទៃ អ. ថ. ញាណៈ ដូចជា ញាណកោសល (—កោសល់) ឈ្មោះជាសមណស័ក្ដិទីកដានណៈសម្រាប់បព្វជិតក្នុងទេសកម្ពុជា ។ ញាណទស្សន ឬ ញាណទស្សនៈ (—ទ័ស-សៈ-នៈ; បា. ញាណទស្សន; សំ. ជ្ញានទស៌ន) ប្រាជ្ញាដែលដឹង ដែលឃើញនូវសេចក្ដីពិត ដូចឃើញច្បាស់នូវសេចក្ដីមិនទៀងនៃរូបកាយជាដើម; បច្ចវេក្ខណញ្ញាណ គឺប្រាជ្ញាសម្រាប់ពិចារណានូវសង្ខារ ... ។ ញាណប្បកាស (ញាណ័ប-ប៉ៈ-កាស; បា.; សំ. ជ្ញានប្រកាស) ពន្លឺនៃសេចក្ដីដឹង គឺការយល់ភ្លឺច្បាស់ក្រោមមិនទើសទាក់ ។ ញាណលក្ខណ ឬ ញាណលក្ខណៈ (—ល័ក-ខៈណៈ; បា. ញាណលក្ខណ; សំ. ជ្ញានលក្សណ) លក្ខណៈនៃញាណ គឺគ្រឿងសម្គាល់របស់សេចក្ដីដឹង, ភ័ស្តុតាងដែលសម្ដែងឲ្យដឹងនូវហេតុការណ៍ក៏ពិតមែន ... ។ ញាណវង្ស (—វង់) ឈ្មោះជាសមណស័ក្ដិទីកដានគណៈសម្រាប់ត្រី ក្នុងប្រទេសកម្ពុជា ។ ញាណវិប្បយុត្ត (—វិប-ប៉ៈយុត; បា.; សំ. ជ្ញានវិប្រយុក្ត) ដែលប្រាសចាកសេចក្ដីដឹង; ចិត្តដែលមានតែជំនឿឥតមានសេចក្ដីដឹងការខុសឬត្រូវឡើយ: ធ្វើបុណ្យដោយញាណវិប្បយុត្ត គឺធ្វើបុណ្យកុសលណាមួយដោយជឿជាក់ថាបានបុណ្យ ប៉ុន្តែឥតមានសេចក្ដីដឹងអ្វីប្លែកជាងជំនឿនោះឡើយ; កិច្ចការអ្វីៗ ដែលអ្នកធ្វើតាមតែបង្គាប់គេ ឥតមានយល់ជាក់ខ្លួនឯងសោះ ក៏ហៅថា ធ្វើដោយញាណវិប្បយុត្ត ដែរ ។ ពាក្យផ្ទុយ: ញាណសម្បយុត្ត ។ ញាណសម្បយុត្ត (—ស័ម-ប៉ៈ-យុត; បា.; សំ. ជ្ញានសំប្រយុក្ត) ដែលប្រកបដោយសេចក្ដីដឹង; ចិត្តដែលប្រកបដោយប្រាជ្ញា គឺចិត្តដែលមានជំនឿព្រមទាំងប្រាជ្ញាក់កេនផង: ធ្វើបុណ្យដោយញាណសម្បយុត្ត; កិច្ចការអ្វីៗដែលគេធ្វើដោយការយល់ជាក់ខ្លួនឯង ក៏ហៅថា ធ្វើដោយញាណសម្បយុត្ត ដែរ ។ ពាក្យផ្ទុយ ញាណវិប្បយុត្ត ។ ញាណសង្ការ (—សំការ) ការសន្សំប្រមូល, ប្រមូលសេចក្ដីដឹងទុកឲ្យមានច្រើន ។ ញាណសាស្ត្រ (—សាស្ត្រ ឬ—សាស; បា. ញាណ + សត្ថ; សំ. ជ្ញានសាស្ត្រ) ក្បួនសម្រាប់ទាយ, ក្បួនព្យាករណ៍ ។ ល ។



ញាណ— (មើលក្នុងពាក្យ ញាណ) ។

ញាណី ន. ឬ គុ. (បា.; សំ. ជ្ញានិន៑) អ្នកមានសេចក្ដីដឹង, អ្នកឈ្លាសវៃ, ដែលមានប្រាជ្ញាកាន់វៃ (អ្នកប្រាជ្ញ) ។

ញាត់ កិ. ច្រកដោយរុក, ដោយរុះសុកសង្កត់ឲ្យណែនឲ្យណែន: ញាត់ផ្ទុកក្នុងក្រឡ, ញាត់ករមួចក្រដាសក្នុងបារ ។

ញាតក (ញាតៈក) ន. (បា.; សំ. ជ្ញាតក) ពួកញាតិ (ម. ព. ញាតិ) ។

ញាតស្សាក (ម. ព. ញៀតស្សាក) ។

ញាតា ន. (បា. ញាតុ—ញាតា; សំ. ជ្ញាតា) អ្នកដឹង (អ្នកប្រាជ្ញ) ។

ញាតិ (ញាត) ន. (បា.; សំ. ជ្ញាតិ) អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតាឬខាងបិតា; ដែលហៅថា ញាតិ ៧ សន្តាន ឬ ញាតិ ៧ ជួរ នោះ តាមន័យក្នុងគម្ពីរពុទ្ធសាសនា លោករាប់ថ្នាក់ខាងលើ ៣ ជាន់ គឺថ្នាក់មាតាបិតា ១, ថ្នាក់ជីដូនជីតា ១, ថ្នាក់យាយទួតតាទួត ១; ថ្នាក់ខាងក្រោមខ្លួន ៣ ជាន់ទៀត គឺថ្នាក់កូន ១, ថ្នាក់ចៅ ១, ថ្នាក់ចៅទួត ១ រួមជា ៦ ថ្នាក់, ជា ៧ ថ្នាក់នឹងខ្លួនយើង; មនុស្សទាំងប៉ុណ្ណេះហៅថា ញាតិ ៧ សន្តាន ។ តាមន័យក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរ ឲ្យរាប់ផ្ទុយថា អ្នកដែលកើតចេញមកពីគោត្រតែមួយ ហៅថា ញាតិ; មាន ២ ពួក គឺ ញាតិជួរខ្សែផ្ទាល់ មួយពួក, សាខាញាតិ មួយពួក; ញាតិជួរខ្សែផ្ទាល់នោះ គឺអ្នកដែលកើតត

ញាតិ ៦ ទៅ ៦ តាមលំដាប់ គឺ ឪពុក, កូន, ចៅ, ចៅទួត ។ល។ រហូតដល់ជាន់ទី ៨, ញាតិផ្លូវនេះតាមតែថ្នាក់ណាក៏ដោយ ច្បាប់ហាមមិនឲ្យយកគ្នាធ្វើប្ដីប្រពន្ធឡើយ; ឯសាខាញាតិនោះ គឺអ្នកដែលកើតចេញពីពោះម្ដាយជាមួយគ្នាដែរ តែបែកទៅជាមែកធាងទៃ ដូចយ៉ាង បងប្អូនបង្កើត, មាមីងនិងក្មួយ, បងប្អូនជីដូនមួយ ជីទួតមួយចុះរៀងទៅ; ញាតិខាងពីរខាងនេះ ច្បាប់អនុញ្ញាតឲ្យយកគ្នាធ្វើប្ដីប្រពន្ធបាន គឺត្រឹមថ្នាក់ទី ៤ គឺពីត្រឹមបងប្អូនជីដូនមួយចុះរៀងទៅ ។ សព្ទនេះ បើរៀងក្រាប់ពីខាងដើមសព្ទដទៃទៀត អ.ថ. ញា-តិ ដូចជា *ញាតិកម្ម* (–កំម; បា.; សំ. *ជ្ញាតិកម៌ន៑*) កិច្ចការ, មុខការរបស់ញាតិ ។ *ញាតិកិច្ច* (–កិច; បា.; សំ. *ជ្ញាតិក្ឫត្យ*) ការងាររបស់ញាតិ ។ *ញាតិគារវៈ* (–គារៈវៈ; បា. *ញាតិគារវ*; សំ. *ជ្ញាតិគៅរវ*) សេចក្ដីគោរពចំពោះញាតិ គឺសេចក្ដីយកចិត្តទុកដាក់ ខ្លះសម, ទទួលទោស, កោតខ្លាចញាតិតាមជាន់ តាមថ្នាក់ ។ *ញាតិជោយសារ* (ញាតជោយសា) អ. ក. *ញាតិពន្ធ* ឬ *ញាតិជោយពន្ធ* ។ *ញាតិទាយាទ* (ញា-តិ-ទាយាត) ទ្រព្យសម្បត្តិរបស់ញាតិ; អ្នកដែលត្រូវទទួលទ្រព្យសម្បត្តិរបស់ញាតិ; កូនប្រុសស្រីរបស់ញាតិ ។ *ញាតិធម៌* (ញា-តិ–) ធម៌របស់ញាតិ; សេចក្ដីសង្គ្រោះដល់ញាតិ : *អ្នកដែលបានធ្វើបុណ្យឧទ្ទិសផល ជូនដល់បុព្វបុរសជាតិខ្មែរ ឈ្មោះថាបានបំពេញញាតិធម៌ដ៏សមគួរហើយ* ។ *ញាតិធីតា* (–ធិតា; បា. *ញាតិធីតុ* > *ញាតិធីតា*; សំ. *ជ្ញាតិទុហិត្ឫ*) កូនស្រីរបស់ញាតិ ។ *ញាតិបុត្ត* ឬ *ញាតិបុត្រ* (–បុត; បា. *ញាតិបុត្ត*; សំ. *ជ្ញាតិបុត្រ*) កូនប្រុសរបស់ញាតិ ។ *ញាតិប្រេត* (–ប្រេត; បា. *ញាតិបេត*, *ញាតិបេ្យត*; សំ. *ជ្ញាតិប្រេត*) ប្រេតដែលជាញាតិ; ញាតិដែលបែកឋាន ទៅកាន់បរលោកហើយ : *ឧទ្ទិសចំណែកបុណ្យជូនទៅញាតិប្រេត* ។ *ញាតិពន្ធ* ឬ *ញាតិជោយពន្ធ* (ញាត-ព័ន; បា. *ញាតិ + ពន្ធ*) ជនដែលគេរាប់ថាជាញាតិ ដោយជាប់ទាក់ទងនឹងគ្នា គឺញាតិជោយសារ ដូចយ៉ាង ម្ដាយក្មេក, ឪពុកក្មេក, កូនប្រសា, មាមីងក្មេក, បងថ្លៃ, ប្អូនថ្លៃ (ខាងប្ដី ឬខាងប្រពន្ធ) ។ល។ *ញាតិពលី* (–ព:លី; បា. *–ពលិ*; សំ. *ជ្ញាតិ–*) ពលីការដែលគេធ្វើដល់ញាតិ, ការសង្គ្រោះញាតិ (ម. ព. *ពលី*, *ពលីការ* ផង) ។ *ញាតិភេទ* ឬ *ញាតិសម្ភេទ* (–ភេត ឬ –សំភេត) ការបែកបាក់នៃញាតិ, ដំណើរបែកខ្ញែកពីញាតិ ។ *ញាតិវង្ស* (–វង់) ពំណនៃញាតិ, ពូជញាតិ (ប្រើជា *ញាតិវង្ស*, *ញាតិពង្ស*, *ញាតិពង្ស* ក៏មាន) ។ *ញាតិវង្សានុវង្ស* (–វង់-សា-នុ-វង់) ពំណនៃញាតិដែលជាប់តវង្សត្រកូលគ្នាពាស់ពាំងពីដូនតាមក ។ *ញាតិវិវាទ* (–វិវាត) សេចក្ដីទាស់ទែងនៃញាតិ, ជម្លោះនៃពួកញាតិ ។ ពាក្យផ្ទុយ *ញាតិសាមគ្គី* ។ *ញាតិសង្គហៈ* ឬ *ញាតិសង្គ្រោះ* (–សង់គៈហៈ ឬ –សង់គ្រោះ) ការទំនុកបម្រុងដល់ញាតិ, ការជួយដោះទុក្ខធុរៈញាតិ ។ *ញាតិសន្តាន* (ញាត-សន្ដាន; បា. *ញាតិ + សន្តាន*; សំ. *ជ្ញាតិ + សន្តាន*) ពំណរ៉ឺវង្សនៃញាតិ; ត្រកូលដែលជាប់ជាញាតិ (ម. ព. *ញាតិ* និង *សន្តាន* ផង)។ *ញាតិសាមគ្គី* (ញា-តិ-សាម៉ុក-គី) សេចក្ដីព្រមព្រៀងរបស់ញាតិ ។ ពាក្យផ្ទុយ *ញាតិវិវាទ* ។ *ញាតិសាលោហិត* (ញា-តិ– ឬ ញាតសា-លោ-ហិត; បា.; សំ. *ជ្ញាតិ + ស្វលោហិត*) ញាតិដែលជាប់ខ្សែលោហិតជាមួយគ្នា... (ម. ព. *សាលោហិត* ផង) ។



**ញាតិ** — (មើលក្នុងពាក្យ *ញាតិ*) ។

**ញាប់** គុ. កិ. ឬ គុ. បន្ទាន់ ញឹកៗ, រហ័ស : *ដើរញាប់ជើង, និយាយញាប់; ដំណើរញាប់, សម្ដីញាប់* ។ ពាក្យផ្ទុយ *យឺត, យារយារ, មួយៗ* ។

**ញ៉ាប** ន. ដំបូលដែលបន្ទាបពីសំយាបផ្ទះឬរោងចុះមក : *តញ៉ាបផ្ទះ, តញ៉ាបរោង* ។

**ញ៉ាម** គុ. ជាប់ចិត្ត, ជៀនចិត្ត : *ឆ្មាបានស៊ីត្រីញ៉ាមឆ្ងាញ់ហើយ វាចេះតែញ៉ាមមកទៀត* ។ ពាក្យផ្ទុយ : *ត្រាន់, ណាយចិត្ត, រអាល* ។

**ញាស់** គុ. កើតចេញពីស៊ុត (តិចង); និយាយចំពោះតែសត្វដែលជាអណ្ដែង : *កូនមាន់ទើបនឹងញាស់* ។ ព. ប្រ. *តាំងពីកញាស់ឡើង* តាំងពីកកើតមក ។

**ញិកញ៉ក់** គុ. កិ. ឬ គុ. ដែលញ័ករញ័ក រញីរញ៉ៃ ដោយអាការមាយា (ប្រើនិយាយចំពោះតែស្រី ឬក្មេង) : *ដើរញិកញ៉ក់; ដំណើរញិកញ៉ក់, មុខញិកញ៉ក់* (ម. ព. *ញុំញី* ផង) ។

**ញិញញ៉ុញ** គុ. កិ. ឬ គុ. ច្រំច្រុម, តិចតួច : *ដើរញិញញ៉ុញ; ដំណើរញិញញ៉ុញ* ។

**ញិម** ឬ **ញឹម** គុ. ចេះតែនោះ; ពាក្យទំលើនិងក្មេង; ដូចគ្នានឹងពាក្យ *ប៉ម, ម៉ុម, ហាំ* ដែរ ។

**ញិល** គុ. កិ. ដែលទៅដោយរហ័ស (ប្រើចំពោះតែសត្វតូចៗ ដែលស្ទុះ) : *ស្ទុះញិល* ។ ដែលផ្លុតក្រោយយ៉ាងរហ័ស (ប្រើចំពោះតែសត្វដែលហើរ) : *ហើរញិល* ។

**ញី** ១ គុ. ឈ្មុះរបស់ស្លិតៗ ឬរបស់ដែលមានសាច់ទន់ : *ញីម្រេច, ញីសំពត់* ។

**ញី** ២ គុ. ដែលមានភេទជាស្រី; ប្រើចំពោះតែសត្វតិរច្ឆាននិងឈើខ្លះ : *មេញី; ត្នោតញី* ។ ព. ផ្ទ. *ឈ្មោល* ។

**ញីញញួញ** គុ. ញញើតញញើម, ស្ទាក់ស្ទើរ ។

**ញឹក** គុ. កិ. ឬ គុ. ដែលមិនឃ្លាត, ជិតៗគ្នា : *ស្ទូងញឹក, ក្រឡាញឹក, សរសេរអក្សរញឹកគ្នាពេក* ។

**ញីកៗ** កិ. វិ. រឿយៗ : *មកញីកៗ* ។

**ញីង** កិ. ចាប់ច្បិចយួរឡើង : *ញីងត្រចៀកឆ្មា* ។

**ញីន** កិ. ស្រាក, អន់, ធន (ច្រើនប្រើតែនឹងពាក្យបដិសេធថា មិន) : *ក្មេងនេះទំលាក់ខ្ញុំស្ដីឲ្យណាស់ដែរ តែកមិនញីនសោះ* ។

**ញឹម** (ម. ព. *ញញឹម*) ។

**ញុំញ** កិ. ស្រញ : *ញុំញកិលទិត* ។

**ញុំៗ** (ម. ព. *ញ៉ុំៗ*) ។

**ញុះ** កិ. និយាយចាក់រុកតាំងអុចអាល ឲ្យខឹងតែខឹង ឲ្យតែក្ដៅឡើង : *ញុះឲ្យបែកសាមគ្គី* ។

**ញុះញង់** កិ. ញុះញុយៗ គឺនិយាយចាក់រុកតាំងអុចអាល ឲ្យអ្នកដទៃធ្វើការអ្វីដែលមិនគប្បី, ឲ្យឈ្លោះទាស់ទែងគ្នា, ឲ្យបាក់បែកគ្នា : *កុំនិយាយញុះញង់ឲ្យកើតហិនសាមគ្គីគេ, គេនៅសុខៗ កុំយកញុះញង់ឲ្យបែកគ្នា* ។

**ញូញ** ១ ន. អ្វីៗ, ព្រមិនៈ សម្រាប់និយាយផ្សំជាមួយនឹងពាក្យ *ខ្ញៅ* : *ខ្ញៅញូញ* ។

**ញូញ** ២ កិ. ញញក, ស្អុញ, ព្រាន់ចិត្ត (មិនសូវប្រើ) ។

**ញូញញ៉ាញ** កិ. ឬ កិ. វិ. ខ្ញាញាញ, ស្ទើរមិនស្ទើរហើយ (និយាយរំភោះតែម្ដង) ។

**ញើក** កិ. ស្ទួយ, ស្ទុះ (ពាក្យប្រើក្នុងល្បែងផ្សេងៗ)។

**ញើញ** កិ. ភិតភ័យ, ចិត្តព្រួញ ។

**ញើបៗ** កិ. សន្សើមៗ, ស្រើបៗ, ល្មមៗ, ពើតខ្លួនដើរយឺតៗ : *ដើរញើបៗ* ។

**ញើស** ១ កិ. បញ្ចេញសំលេងតិចព្រមុះ : *ញើសសំបោរ, សំពៀតទប់ញើសមិនចេញ* ។

**ញើស** ២ ន. អាការៈរាវ (ជាតុទឹក) ដែលចេញពីខ្លួនតាមរន្ធរោមដោយចំហាយ : *ទំលើរតាល់តែបែកញើស* ។

**ញៀប** កិ. ចាប់ស៊ីកន្រ្តៀបគន្រង់ (ពាក្យក្នុងល្បែងលេងបិទក្ខំ) : *លេងឈ្នះបានញៀបតួកក់ហើយ* ។

**ញៀក** កិ. សៀតញាត់ក្នុងកន្លៀត ។

**ញៀតស្បាត** គុ. ដែលតឹកជ្រៀតជុំកជិតដោយស្មៅឬស្បូវនឹងឈើតូចៗ : *ព្រៃញៀតស្បាត* ។ ហៅថា *ញៀតញីក* ក៏បាន; ពួកណាហៅត្រឹមតែ *ញៀត* ក៏បាន : *ព្រៃនុំញៀតក្រាស់ណាស់* ។ ប្រើជា ន. ក៏មាន : *ទំនោះមានសុទ្ធតែញៀតស្បាត មិនអាចចូលទៅបានទេហយឆាយទេ* ។ អ្នកស្រុកខ្លះនិយាយថា *ញាតស្បាត* (គួរប្រើ *ញៀតស្បាត* វិញ) ។

**ញៀន** កិ. ជាប់ចិត្តដោយមានចំណង់ អត់មិនបានដោយធ្លាប់ប្រព្រឹត្ត, ធ្លាប់ជក់, ធ្លាប់ស៊ី សុះផល់កំណត់, ដល់វេលាដែលធ្លាប់ ក៏បណ្ដាលឲ្យនឹកជង់អត់មិនបានឬក៏ទៅជាធ្វើខ្លួនឲ្យស្រួលខ្លួន : *ញៀនមើលល្បែង, ញៀនកាកៀន* ។



**ញេញ** កិ. ទាំស្រាលៗដោយធ្មេញ ឬទាំធ្មេញដោយកំហឹង : *ញេញមួ, ញេញធ្មេញ* ។

**ញេច** កិ. សង្កត់ល្មេចបំបែក, បំពៀច : *ញេចសន្ទិច, ញេចចែច* ។

**ញ៉េចញ៉ោច** ខ. សូរក្ដុកក្ដេងឬក្ដុកសត្វច្រើនយំឬស្រែកៗ

**ញ៉េចញ៉ូច** កិ. ឬ កិ. វិ. បេញបួញ ។

**ញ៉េបៗ** ខ. សូរកូនសត្វស្លាបយំ ។

**ញេយ្យធម្ម** ឬ **ញេយ្យធម៌** (ញេ-យៈធ័ម ឬ —ធ័រ) ន. (បា. *ញេយ្យធម្ម*; សំ. *ជ្ញេយធម៌*) ធម៌ដែលអ្នកប្រាជ្ញគួរដឹង; ធម៌ដែលព្រះសព្វញ្ញុតញ្ញាណត្រាស់ដឹង : *ព្រះអង្គទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង* ។

**ញ៉ើរ** គុ. ដែលខ្លួនតឹងស្ពានដោយគិតត (សំឡេង) : *សំឡេងញ៉ើរ* ។

**ញ៉ើរញ៉ារ** ខ. សូរសំឡេងតូចធ្មាយ ។

**ញ៉េះញ៉ោះ** កិ. ឬ កិ. វិ. រឡេះរឡោះដោយលេងដោយប្រុងទុក : *និយាយញ៉េះញ៉ោះ* ។

**ញែ៉** គុ. ដែលខ្លួចធ្មារហើយស្អកផង (សំឡេង) : *សំឡេងញែ៉* ។

**ញែក** កិ. វែកចេញ, កាត់ចេញ, ចែកចេញ ។

**ញ៉ែកញ៉ក** ខ. សូរសព្វក្រុកមាន់ (ខ្ទក់ៗ) ។

**ញ៉ែង** ន. របាំងមិនដែលគេធ្វើជាក្រោល ។

**ញ៉ែងញ៉ង** កិ. វិ. ឬ គុ. ចង្អៀត, ចង្អុត, ល្អាសល្អត់ : *រើរញ៉ងញ៉ង; ដំណើរញ៉ងញ៉ង* ។

**ញ៉ែមៗ !** ឧ. ពាក្យសម្រាប់ពោលបញ្ចៀមគេ (ម. ព. *បញ្ចៀម* ផង) ។

**ញ៉ៃង** គុ. ដែលច្រើស, ដែលប្រសើរជាងគេ ។

**ញោច** ១ កិ. ចេញ; លូកចេញឬលូកចូល ។

**ញោច** ២ ន. រំពត់, របស់ដែលលូកចេញឬលូកចូល។

**ញោម** ប. ស. ពាក្យសម្រាប់បព្វជិតហៅមាតាបិតាបង្កើតឬមាតាបិតាចិញ្ចឹម : *ញោមប្រុស* គឺឪពុក, *ញោមស្រីកា* ឬ *ញោមស្រី* គឺម្ដាយ; ឬមាតាបិតាដទៃទៀតដែលមានចំណាស់ ប្រហែលនឹងមាតាបិតារបស់ខ្លួន បព្វជិតក៏ហៅ *ញោម* បានដែរ ។ *ញោមញាតិ* ឬ *ញាតិញោម* ពាក្យសម្រាប់បព្វជិតហៅពួកឧបាសកឧបាសិកាដោយប្រុប : *វត្តនេះមានញាតិញោមជើងវត្តច្រើនណាស់ : សូមឲ្យញាតិញោមទំនៀងធម៌ កាន់សីល ប្រព្រឹត្តសុចរិត កាន់ចិត្តស្មោះត្រង់ត្រូវគ្នាឡើង ដើម្បីបានសេចក្ដីសុខចម្រើនកើនឡើងទៀត* ។

**ញោមវត្ត** (—វ័ត) *ន.* ឧបាសកអ្នកចេញមុខទំនុកបម្រុង ផ្គត់ផ្គង់វត្តអារាមណាមួយ (ម. ព. *អកមិកជន* ផង) ។

**ញោស** *គុ.* ដែលទុំជ្រុលហួសពីធម្មតា : *ផ្លែស្វាយទុំញោស* ។ ដែលចាស់គ្រាំគ្រាទ្រុឌទ្រោមខ្លាំង : *ចាស់ញោស* ។ *កិ. វិ.* ដែលជ្រុលហួសប្រមាណ, ហួសហេតុ : *ទំនឹងញោស, ស្ដីជេរប្រឡោសញោសពេកណាស់* ។

**ញោះ** *កិ.* ការគោះចុះដោយចុងដំបង, ចុងអន្លូង, ចុងម្រាមដៃជាដើម ។ ព. ប្រ. គោះ, សំគាល់ដោយសម្ដី : *ត្រូវញោះមួយម៉ាត់ទៅ គាត់ប្រាប់ឡូតតួន* ។

**ញុំ ៗ** *កិ.* ឬ *កិ. វិ.* បុកឬទំពាបន្តើរ ៗ, សំរ ៗ : *ទំពាញុំ ៗ, បុកញុំ ៗ* ។

**ញាំ** ១ *កិ.* ធ្វើម្ហូបដែលគេហៅថា *ញាំ* ។

**ញាំ** ២ *ន.* អាហារធ្វើដោយគ្រឿងផ្សេងៗ មានត្រីអាំងឬត្រីស្ងោរជាដើម ច្របល់បញ្ចូលគ្នានឹងគ្នា (មិនចម្អិនទៀតទេ) : *ញាំសាឡាត់, ញាំត្រសក់* ។

**ញុំា** *កិ.* ស៊ី; និយាយចំពោះតែកូនក្មេងតូច (ពាក្យទំយើ) : *អាពៅញុំាបាយខ្លួនឯងហើយ* ។

**ញុំាង** *សា. និ.* ប្រើ, បង្គាប់ : *គ្រូញុំាងសិស្សឲ្យរៀន, ញុំាងចិត្តឲ្យជ្រះថ្លា* ។ (នុះកុំប្រើថា *គ្រូញុំាងឲ្យសិស្សរៀន*) ។ *ញុំាងឈ្មោះ* គឺញុំាងឲ្យឈ្មោះឲ្យកើតមានឡើង (សម្រាប់ប្រើក្នុងកាព្យ) : *កុំនៅញុំាងឈ្មោះ កុំស្លាប់អសុរោះ កុំស្លាប់គាស្រូវ កុំដើរពាលស្លុត កុំស្ពាក់ប្រកផ្លូវ កុំធ្វើស្រែស្រូវ នៅផ្លូវដើរ* ។ ... (សាស្ត្រាច្បាប់ *កេរនេតិ* ជាព្រះនិពន្ធនៃព្រះភគស្ដារ) ។

**ញុំាង ៗ** *ន.* សូរសព្ទក្មេង ដែលមានសំឡេងស្រួយខ្ទរ ខ្ទង ។ *កិ. វិ.* ខ្ទង ៗ ខ្ទាង ៗ : *និយាយញុំាង ៗ* ។

**ញុំាញុី** *កិ. វិ.* ឬ *គុ.* ញ៉ិកញ៉ាក់, ញ៉ែងញ៉ង : *ដើរញុំាញុី, ដំណើរញុំាញុី* ។